**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**អគ្គនាយកដ្ឋានកសិកម្ម**

លេខ......៤២៧......អ.ន.ក

ថ្ងៃ...សុក្រ ២កើត...ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី....០៨....ខែ.....មីនា.....ឆ្នាំ២០១៩

**សូមគោរពជូន**
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**កម្មវត្ថុ៖** របាយការណ៍ស្តីពីសកម្មភាពអនុវត្តការងារប្រចាំខែកុម្ភៈ ឆ្នាំ២០១៩ របស់អគ្គនាយកដ្ឋានកសិកម្ម។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមអនុញ្ញាតរាយការណ៍ជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបនូវលទ្ធផលអនុវត្តសកម្មភាពការងាររបស់អគ្គនាយកដ្ឋានកសិកម្មប្រចាំខែកុម្ភៈ ឆ្នាំ២០១៩ មានដូចខាងក្រោម៖

## I. លទ្ធផលបង្កបង្កើនផលកសិកម្មរដូវប្រាំងឆ្នាំ២០១៨ (គិតត្រឹមថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩)

១. ដំណាំស្រូវ : ផ្ទៃដីស្ទូងព្រោះសរុបអនុវត្តបានចំនួន ៥៨៩.៥០៤ ហ.ត ស្មើនឹង១៣១,៧៣ % នៃផែនការចំនួន ៤៤៧.៥០០ ហ.ត លឿនជាងឆ្នាំមុនចំនួន ៤៦.៣៨៤ ហ.ត

- ការងារភ្ជួររាស់ដី : ផ្ទៃដីភ្ជួររាស់សរុបអនុវត្តបានចំនួន ៦២៥.៩៦៧ ហ.ត លឿនជាងឆ្នាំមុនចំនួន ៧០.៥៩៥ ហ.ត ក្នុងនោះផ្ទៃដីភ្ជួររាស់ដោយគ្រឿងយន្តចំនួន ៦១៨.៩២៨ ហ.ត ស្មើនឹង១៣១,៧៣% នៃផ្ទៃដីភ្ជួររាស់សរុប
- ផ្ទៃដីសាបសរុប : ១៧៣ ហ.ត យឺតជាងឆ្នាំមុនចំនួន ៣០២ ហ.ត។







*ក្រាហ្វិក៖ ស្ថិតិផ្ទៃដីភ្ជួររាស់ និងដាំដុះស្រូវរដូវប្រាំងពីឆ្នាំ២០១៥-២០១៩ គិតត្រឹម ចុងខែកុម្ភៈនៃឆ្នាំ*

- ប្រៀបធៀបផ្ទៃដីភ្ជួររាស់ និងដាំដុះដំណាំស្រូវរដូវប្រាំងរយៈពេល៥ឆ្នាំចុងក្រោយ គិតត្រឹមចុងខែកុម្ភៈ បង្ហាញថាទាំងផ្ទៃដីភ្ជួររាស់ និងដាំដុះដំណាំស្រូវរដូវប្រាំងឆ្នាំ២០១៨-២០១៩ អនុវត្តបានច្រើនជាងបណ្តាឆ្នាំមុនៗ។

២. ដំណាំរួមផ្សំ : អនុវត្តបានចំនួន ៣៧.១៨០ ហ.ត លឿនជាងឆ្នាំមុនចំនួន ៥.២៩០ ហ.ត។

៣. ដំណាំឧស្សាហកម្ម : អនុវត្តបានចំនួន ៨២.០៦៦ ហ.ត យឺតជាងឆ្នាំមុនចំនួន ៧.៦២៨ ហ.ត។


អាសយដ្ឋានលេខ: ៥៤បេ/៤៩អេហ្វ ផ្លូវលេខ ៣៩៥-៦៥៦ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ទូរស័ព្ទលេខ:(០២៣) ៨៨៣ ៤២៧ ទូរសារលេខ:(០២៣) ៨៨៣ ៤២៧
Address # 54B/49F, Street 395-656, Sangkat Toeuk Laak 3, Khan Tuol Kok, Phnom Penh. Cambodia, Phone : (023) 883 427, Fax : (023) 883 427